### បណ្ដាញសហគមន៍ ព្រៃឡង់
### ព្រៃឡង់ ជាព្រៃរបស់យើងទាំងអស់គ្នា

PREY LANG
IT'S OUR FOREST TOO

# សេចក្ដីប្រកាសព័ត៌មាន ស្ដីពី
# ការពន្យារពេល ប្រារព្ធពិធីបុណ្យព្រៃឡង់ និងបំបួសដើមឈើ

យើងខ្ញុំទាំងអស់គ្នា ជាតំណាងគណៈកម្មការ បុណ្យព្រៃឡង់ និងបំបួសដើមឈើ និងជាសមាជិក បណ្ដាញសហគមន៍ព្រៃឡង់ទាំងបួនខេត្ត ក្រចេះ ស្ទឹងត្រែង ព្រះវិហារ និងកំពង់ធំ សូមប្រគេន និងជម្រាបជូនដំណឹងដល់ ព្រះតេជព្រះគុណ លោក លោកស្រី នាងកញ្ញា សិស្សនិស្សិត សាសនិកជន សប្បុរសជនជិតឆ្ងាយ និងសាធារណជនជនទូទៅ មេត្តាជ្រាបថា **គណៈកម្មការបុណ្យ បានពិភាក្សាសម្រេចពន្យារពេលប្រារព្ធពិធីបុណ្យព្រៃឡង់ និងបំបួសដើមឈើ** ដែលគ្រោងនឹងប្រារព្ធនៅថ្ងៃទី២៦ និង២៧ ខែមីនា ឆ្នាំ២០១៨ រហូតដល់មានការប្រជុំសម្រេចជាថ្មី។

យើងខ្ញុំសូមប្រគេន និងជម្រាបជូនថា ការពន្យារពេលប្រារព្ធពិធីបុណ្យព្រៃឡង់ និងបំបួសដើមឈើនេះ ព្រោះតែបណ្ដាញសហគមន៍ព្រៃឡង់ជួបនូវស្ថានភាពដូចខាងក្រោម៖

**១. សមាជិកបណ្ដាញសហគមន៍ព្រៃឡង់មានការមមាញឹកប្រមូលភោគផលកសិកម្មសម្រាប់ជីវភាពប្រចាំថ្ងៃ និង**
**២. ទីកន្លែងប្រារព្ធពិធីបុណ្យព្រៃឡង់ និងបំបួសដើមឈើ មិនមានអំណោយផល។**

សូមប្រគេន និងជម្រាបជូនបន្ថែមថា **ថវិកាបដិភាគ** ដែលព្រះករុណាយើងខ្ញុំជាតំណាងបណ្ដាញសហគមន៍ព្រៃឡង់ទទួលបានពី ព្រះតេជព្រះគុណ លោក លោកស្រី នាងកញ្ញា សិស្សនិស្សិត សាសនិកជន សប្បុរសជនជិតឆ្ងាយ នាពេលកន្លងមក **នឹងរៀបចំចាត់ចែងផ្ញើត្រឡប់ទៅកាន់សាមីដើមវិញ** តាមចំនួនទឹកប្រាក់ដែលបានផ្ញើមកព្រះករុណាយើងខ្ញុំ **ឬក៏រក្សាទុកនឹងគណៈកម្មការដោយមានការព្រមព្រៀងពីម្ចាស់ថវិកាបដិភាគ។**

សេចក្ដីដូចបានប្រគេន និងជម្រាបជូនខាងលើនេះ ព្រះករុណាយើងខ្ញុំទាំងអស់គ្នា សូមខមាទោស អភ័យទោស និងយល់អធ្យាស្រ័យពីសំណាក់ ព្រះតេជព្រះគុណ លោក លោកស្រី នាងកញ្ញា សិស្សនិស្សិត សាសនិកជន សប្បុរសជនជិតឆ្ងាយ និងសាធារណជនទូទៅ ចំពោះការពន្យារពេលប្រារព្ធពិធីបុណ្យ ដែលបណ្ដាលមកពីការរៀបចំចាត់ចែងកម្មវិធីមិនបានល្អ និងត្រឹមត្រូវពីគណៈកម្មការរៀបចំ។

ដើម្បីជ្រាបព័ត៌មាន ឬមានចម្ងល់ពីការពន្យាពេលនេះ សូមទំនាក់ទំនងតំណាងគណៈកម្មការដូចខាងក្រោម៖


១. លោក ហឿន សុភាព ០១២ ៣៧៣៤៤១/០៩៦ ៦៣២ ៨៥៧៣
២. លោក ស្រី ចី ០៩៩ ៧២២ ១៨៧
៣. លោក ឯក សុវណ្ណា ០៩៧ ៦៤៤ ៩៩៩៨/០៩៨ ៨៤៥ ៩៧៩
៤. លោក ជា សុខហឿន ០៨៨ ៥១០ ០៥៨៨/០៩៦ ៣១៦ ២៨៦៦


*សូមអរព្រះគុណ និងអរគុណ!*